# ពិធីលេងកំសាន្តក្នុងថ្ងៃចូលឆ្នាំ

នៅរៀងរាល់ថ្ងៃនិងយប់ ក្រោយពីបានស្តាប់ព្រះសង្ឃចំរើនព្រះបរិត្ត ទេសនា សូត្រជារបង្សុ-កូល ចាស់ទុំ ក្រមុំ កំលោះ ក្មេងក្មាង បានប្រមូលផ្តុំគ្នា នៅក្នុងវត្តក៏មាន នៅតាមភូមិក៏មាន នៅតាមផ្ទះក៏មាន ភាគច្រើននៅតាមវត្ត ក្រោមម្លប់ឈើធំៗ ក្រសាលលេងល្បែងប្រជាប្រិយផ្សេងៗ ទៅតាមចំណង់ចំណូលចិត្ត មាចាប់កូនខ្លែង, លាក់កន្សែង, ក្រុងមាន់, ទាញព្រ័ត្រ, ស្តេចចង់, ចោលឈូង, រាំវង់, ។ល ។ ដែលជាប្រពៃណីរបស់ខ្មែរ ជៀសវៀងកុំលេងល្បែងណា ដែលនាំឱ្យ អន្ត-រាយដល់ទ្រព្យសម្បត្តិ និងអាយុជីវិត ។ កុំប្រព្រឹត្តនូវអំពើអបាយមុខ ដែលជាហេតុនាំឱ្យ សេចក្តីក្តៅក្រហាយក្នុងបច្ចុប្បន្ន និងមានដំណើរអាក្រក់ទៅក្នុងបរលោក ។ ពេលនេះទឹកមុខគេម្នាក់ៗ រីករាយស្រោះស្រាយ សប្បាយក្អាកក្អាយទៅរកគ្នានិងគ្នា សំឡេងស្រែកហ៊ោឡើងលាន់ឮយ៉ាងខ្ញៀវខ្ញារ ។ គេម្នាក់ៗ ហាក់ដូចជាគ្មាននឿយហត់អ្វីបន្តិចបន្តួចសោះ ក្នុងពេលកំពុងលេងកំសាន្ត នេះបញ្ជាក់ថាគេទាំងអស់គ្នាពេញចិត្ត នឹងល្បែងប្រជាប្រិយដែលជាប្រពៃណីខ្មែរ នឹងពេញចិត្តក្នុងការអបអរសាទរពេលចូលឆ្នាំថ្មី ព្រមទាំងសប្បាយរីករាយ នឹងទេវតាឆ្នាំថ្មី ដែលបាន ចុះមករក្សាមនុស្សលោក ។